# ស្ថានទូតអូស្ត្រាលី ភ្នំពេញ

## <u>សេចក្តីប្រកាសព័ត៌មាន</u>

ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០២១

## ការគាំទ្ររបស់អូស្ត្រាលីក្នុងការផ្តល់សេវានៃការធ្វើតេស្ត និងការបង្ការជំងឺអេដស៍

ប្រទេសអូស្ត្រាលីកំពុងវិនិយោគទឹកប្រាក់ ១១,៦៥លានដុល្លាអូស្ត្រាលី ដើម្បីបង្កើននូវចំនួននិងការទទួលបាននូវសេវាធ្វើតេស្ត និងការបង្ការជំងឺអេដស៍ ក្នុងចំណោមប្រជាពលរដ្ឋគោលដៅ ក្នុងតំបន់ឥណ្ឌូប៉ាស៊ីហ្វិច។ នៅកម្ពុជា ការវិនិយោគថ្មីនេះ នឹងជួយដល់អង្គការដឹកនាំដោយសហគមន៍ ធ្វើឲ្យប្រសើរឡើងនូវសេវាបង្ការនិងការធ្វើតេស្ត ក៏ដូចជាដោះស្រាយបញ្ហាវិសមភាព ការឈឺចាប់ផ្លូវចិត្ត និងការរើសអើង ជូនអ្នកដែលកំពុងតែរស់នៅជាមួយជំងឺអេដស៍។

ថ្ងៃនេះ លោក **Andreas Zurbrugg** អនុប្រធានបេសកកម្មប្រចាំស្ថានទូតអូស្ត្រាលី និងលោកស្រីវេជ្ជបណ្ឌិត **Khin Cho Win Htin** ប្រធានស្តីទីកម្មវិធីរួមគ្នារបស់អង្គការសហប្រជាជាតិប្រយុទ្ធជំងឺអេដស៍ **(UNAIDS)** រួមជាមួយឯកឧត្តមវេជ្ជបណ្ឌិត ទៀ ផល្លា អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងជំងឺអេដស៍ និងលោកវេជ្ជបណ្ឌិត លី ប៉េងស៊ុន នាយកមជ្ឈមណ្ឌលជាតិប្រយុទ្ធប្រឆាំងជំងឺអេដស៍ និងកាមរោគ មានសេចក្តីរីករាយ ក្នុងការដាក់ឲ្យដំណើរការកម្មវិធីនៃភាពជាដៃគូថ្មីជាមួយ កម្មវិធីរួមគ្នារបស់អង្គការសហប្រជាជាតិប្រយុទ្ធជំងឺអេដស៍ **(UNAIDS)**។ ក្រោមការគាំទ្ររបស់អូស្ត្រាលី កម្មវិធីភាពជាដៃគូថ្មីនេះនឹងពង្រឹងការបង្ការការចម្លងជំងឺអេដស៍ តាមរយៈកម្មវិធីបង្ការការចម្លងជំងឺអេដស៍ ២០២១-២០២៣។

លោក **Andreas Zurbrugg** អនុប្រធានបេសកកម្មប្រចាំស្ថានទូតអូស្ត្រាលី បានមានប្រសាសន៍ថា "ប្រទេសអូស្ត្រាលីគឺជាអ្នកនាំមុខគេលើពិភពលោក ក្នុងការប្រយុទ្ធប្រឆាំងជំងឺអេដស៍។ ក្នុងអំឡុងពេលនៃជំងឺរាតត្បាតនេះ អង្គការដឹកនាំដោយសហគមន៍ ឥឡូវនេះលើសពីលើកមុន អាចជួយកែឆ្នៃ ផ្តល់និងក្លាយជាអ្នកផ្តល់សេវាដ៏ចាំបាច់ ក្នុងការឆ្លើយតបទៅនឹងជំងឺអេដស៍ ព្រមទាំងជំងឺកូវីដ-១៩។"

ការឆ្លើយតបរបស់កម្ពុជាលើជំងឺអេដស៍ ដើតួនាទីជាគំរូមួយក្នុងតំបន់ ដោយក្នុងឆ្នាំ២០១៧ បានក្លាយជាប្រទេសមួយក្នុងចំណោមប្រាំពីរប្រទេស លើពិភពលោក ដែលសម្រេចបាននូវគោលដៅជាអន្តរជាតិ ក្នុងការធ្វើតេស្តនិងព្យាបាល ។ ប៉ុន្តែនៅមានកិច្ចការបន្តទៀតដែលត្រូវធ្វើ ដើម្បីជួយធានាថា កម្មវិធីបង្ការនេះនឹងបន្តផ្តល់ដល់ប្រជាជនគោលដៅ ជាពិសេសប្រជាជនដែលយើងពិបាកទៅដល់។

ឯកឧត្តមវេជ្ជបណ្ឌិត ទៀ ផល្លា អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងជំងឺអេដស៍ បានមានប្រសាសន៍ថា "ការប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍នៅកម្ពុជា អស់រយៈកាលរាប់ទស្សវត្សន៍ និងភាពជោគជ័យដ៏ត្រចះត្រចង់របស់យើង ជាឫសក្នុងការផ្តោតទៅលើ នវានុវត្តន៍ ការគោរពសិទ្ធិមនុស្សនិងសមធម៌យេនឌ័រ ដំណោះស្រាយនៅតាមសហគមន៍ និងការប្តេជ្ញាចិត្តផ្នែកនយោបាយ ក៏ដូចជាភាពដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជា។ យើងត្រូវការពង្រីកកិច្ចប្រឹងប្រែងរបស់យើងក្នុង ការបញ្ចប់ជំងឺអេដស៍នៅកម្ពុជា។"

ការវិនិយោគរបស់អូស្ត្រាលី នឹងគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់ប្រទេសកម្ពុជា ក្នុងការកាត់បន្ថយចំនួនអ្នកផ្ទុកមេរោគអេដស៍ថ្មី តាមរយៈ ការធ្វើកិច្ចការដើម្បីលុបបំបាត់បញ្ហាមួយចំនួនទាក់ទងនឹងគោលនយោបាយ ច្បាប់ និងបទប្បញ្ញត្តិ ក្នុងការទទួលបានសេវាកម្មបង្ការ និងធ្វើតេស្តដែលមានគុណភាព បង្កើនសមត្ថភាពនិងគាំទ្រអង្គការសហគមន៍មួយចំនួន ដើម្បីទៅដល់ប្រជាជនគោលដៅ ព្រមទាំងបង្កើននូវការទទួលបានសេវាកម្មដែលមានគុណភាព ដើម្បីបង្កើនផលប្រយោជន៍សុខមាលភាពសម្រាប់ប្រជាជានគោលដៅផងដែរ។

លោកវេជ្ជបណ្ឌិត លី ប៉េងស៊ុន នាយកមជ្ឈមណ្ឌលជាតិប្រយុទ្ធប្រឆាំងជំងឺអេដស៍ និងកាមរោគ បានបន្ថែមថា "យើងកំពុងតែស្ថិតនៅក្នុងពេលវេលាដ៏ល្អមួយ សម្រាប់ការឆ្លើយតបទៅនឹងបញ្ហាជំងឺអេដស៍នៅកម្ពុជា ដោយយើងកំពុងតែដំណើរការឆ្ពោះទៅរកការបញ្ចប់ជំងឺអេដស៍ ខណៈពេលដែលយើងកំពុងតែរក្សាសមិទ្ធិផលរបស់យើង ដែលបានសម្រេចនូវគោលដៅនៃការព្យាបាល ៩០-៩០-៩០។ យើងចាំបាច់ត្រូវតែបង្កើននូវសេវាកម្មបង្ការ សម្រាប់ប្រជាជនគោលដៅ តាមរយៈនវានុវត្តន៍ និងការបង្កើននូវសមត្ថភាពទទួលបាននូវសេវាកម្មបង្ការ ប្រកបដោយសមធម៌។"

លោកស្រីវេជ្ជបណ្ឌិត **Khin Cho Win Htin** ប្រធានស្តីទីកម្មវិធីរួមគ្នារបស់អង្គការសហប្រជាជាតិប្រយុទ្ធជំងឺអេដស៍ **(UNAIDS)** បានកត់សម្គាល់ថា "កម្មវិធីរួមគ្នារបស់អង្គការសហប្រជាជាតិប្រយុទ្ធជំងឺអេដស៍ កំពុងទន្ទឹមរង់ចាំសហការជាមួយអូស្ត្រាលី ដើម្បីបង្កើនចំនួន និងការទទួលបានសេវាធ្វើតេស្តនិងបង្ការមេរោគអេដស៍ ក្នុងចំណោមប្រជាជនគោលដៅក្នុងប្រទេសកម្ពុជា។" លោកស្រីវេជ្ជបណ្ឌិត បានបន្ថែមថា "ក្នុងអំឡុងពេលដែលយើងកំពុងបន្តការប្រយុទ្ធ នឹងការរីករាលដាលនៃរោគរាតត្បាតសកលនេះ យើងត្រូវតែចងចាំថា ការគាំទ្រដល់សេវាសុខភាពចាំបាច់ ដូចជាការបង្ការមេរោគអេដស៍ មានសារៈសំខាន់សម្រាប់ការពារសុខភាព និងប្រយុទ្ធប្រឆាំងនឹងបញ្ហាវិសមភាព ដែលអ្នកកំពុងរស់នៅជាមួយមេរោគអេដស៍កំពុងជួបប្រទះ។"

**ទំនាក់ទំនងព័ត៌មាន៖**

ស្ថានទូតអូស្ត្រាលី៖ Australian.Embassy.Cambodia@dfat.gov.au